**Mekong Watch**
3F Aoki Building 1-12-11 Taito
Taito-ku, Tokyo 110-0016 Japan
E-mail: info@mekongwatch.org
Website: http://www.mekongwatch.org


Lower Sesan 2 under construction
(Photo taken on 27th July 2015)

ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥

# ខ្លឹមសារសង្ខេប

**ផលប៉ះពាល់អវិជ្ជមាននៃទំនប់វារីអគ្គិសនីសេសានក្រោម២មកលើប្រទេសកម្ពុជា៖**

ទំនប់វារីអគ្គិសនីសេសានក្រោម២ បច្ចុប្បន្នកំពុងស្ថិតក្រោមការសាងសង់ គេរំពឹងថាមិនត្រឹមតែនាំឲ្យមានផលប៉ះពាល់អវិជ្ជមានដ៏ធំសម្បើមដល់ទន្លេស្រែពក និង ទន្លេសេសាន នៅភូមិភាគឦសាននៃប្រទេសកម្ពុជាប៉ុណ្ណោះនោះទេ ថែមទាំងធ្វើឲ្យមានគ្រោះមហន្តរាយដល់ប្រជាជនទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋដែលកំពុងរស់នៅតាមទន្លេមេគង្គក្រោមផងដែរ។ ដើម្បីបង្ការនូវបញ្ហានេះ យើងសុំជំរុញឲ្យរដ្ឋាភិបាលនៃប្រទេសកម្ពុជា ចេញអន្តរាគមន៍បញ្ជាឲ្យបញ្ឈប់ការសាងសង់ជាបន្ទាន់ ដើម្បីបង្ហាញនូវរាល់ឯកសារពាក់ព័ន្ធនានា និងបំពេញបន្ថែមនូវការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (អ៊ី អាយ អេ) ដោយជានាអោយមាននូវការចូលរួមយ៉ាងពេញលេញពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសនោះគឺសហគមន៍ដែលរងផងប៉ះពាល់ និងធ្វើការពិនិត្យ ពិចារណាឡើងវិញឲ្យបានល្អិតល្អន់លើគម្រោងនេះ។

**ផលប៉ះពាល់អវិជ្ជមានធំៗដែលនឹងកើតមានឡើង៖**

១. ទំនប់វារីអគ្គិសនីសេសានក្រោម២នឹងរាំងខ្ទប់ចរាចរណ៍របស់ត្រីវាងទន្លេមេគង្គ និងទន្លេស្រែពក/ទន្លេសេសាន។ យ៉ាងហោចណាស់ មានប្រជាពលរដ្ឋចំនួន៧៨០០០នាក់ កំពុងរស់នៅផ្នែកខាងលើនៃទំនប់នេះ នឹងបាត់បង់ការនេសាទត្រីដែលធ្លាប់អនុវត្តតាមរដូវកាល (ការស្រាវជ្រាវរបស់លោកប៊ឺត ២០០៩, Baird, 2009)។ ការកាត់បន្ថយនូវការទទួលទានអហារដែលមានសារជាតុប្រូតេអ៊ីនសម្រាប់អ្នកភូមិទាំងនេះ នឹងក្លាយជាបញ្ហាដ៏ធ្ងន់ធ្ងរមួយជាក់ជាមិនខាន។ ផលប៉ះពាល់អវិជ្ជមានរបស់ទំនប់សេសានក្រោម២នេះ ក៏នឹងកើតមានដល់បឹងទន្លេសាប ក៏ដូចជាអាងទន្លេមេគង្គក្រោម

**Mekong Watch**
3F Aoki Building 1-12-11 Taito
Taito-ku, Tokyo 110-0016 Japan
E-mail: info@mekongwatch.org
Website: http://www.mekongwatch.org

ទាំងមូលផងដែរ។ យោងតាមរបាយការណ៍របស់គណៈកម្មការទន្លេមេគង្គ (អ៊ឹម អ ស៊ី) បានឲ្យដឹងថា ចំនួនប្រជានេសាទនៅក្នុងបឹងទន្លេសាបមានជំនួនរហូតដល់ទៅ១,២លាននាក់។

២. ការអះអាងពីផលប្រយោជន៍សេដ្ឋកិច្ច គឺនៅតែមានការចោទជាសំណួរ ដែលការប្រតិបត្តិការផលិតថាមពលអគ្គិសនី នឹងត្រូវធ្លាក់ចុះនៅរដូវប្រាំង។ ការប្រៀបធៀបដ៏សាមញ្ញមួយរវាងការរំពឹងទុកលើប្រាក់ចំណូលដែលបានមកពីការផលិតថាមពលអគ្គិសនីពីទំនប់វារីអគ្គិសនីសេសានក្រោម២ និងការបាត់បង់ផលត្រី បានបង្ហាញឲ្យឃើញថា ផលប៉ះពាល់នឹងកាត់តែធ្ងន់ធ្ងរឡើងៗនៅពេលខាងមុខ។ ខណៈដែលទំនប់នេះ រំពឹងថានឹងបង្កើតប្រាក់ចំណូលប្រមាណជា២៩៥៨លានដុល្លាអាមេរិកក្នុងមួយឆ្នាំ (របាយការណ៍របស់អង្គការទន្លេអន្តរជាតិឆ្នាំ២០១៤, IR, 2014), តែតម្លៃផលសរុបដែលទទួលបានផលនេសាទត្រី ដោយគិតត្រឹមតែនៅទន្លេសេសានមួយប៉ុណ្ណោះ គឺមានតួរលេខចាប់ពី ១ ទៅ២៥លានដុល្លាអាមេរិកក្នុងមួយឆ្នាំ(តាមការស្រាវជ្រាវរបស់លោក ប៉ារ៉ាន់ ឆ្នាំ២០១៣, Baran et al., 2013: 16)។

៣. គុណភាពទឹកនៅទន្លេសេសាន និងទន្លេស្រែពកនឹងត្រូវថយចុះ ដោយសារតែអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីនេះ នឹងផ្ទុកទឹកទុកយ៉ាងច្រើន ហើយនឹងបង្ហូរទឹកចេញនៅពេលប្រតិបត្តិការផលិតថាមពលអគ្គិសនី។ ការថយចុះនូវគុណភាពទឹក នឹងបង្កឲ្យមានបញ្ហាសុខភាពដល់សហគមន៍ទាំងឡាយដែលពឹងផ្អែកលើទឹកទន្លេ។

៤. ទំនប់វារីអគ្គសនីសេសានក្រោម២ អាចកាត់បន្ថយដីល្បាប់ទន្លេប្រមាណជា៦%ទៅ ៨%។ មិនមានសារជាតុចិញ្ចឹមគ្រប់គ្រាន់ត្រូវបានហូរបញ្ជូនទៅដល់ខ្សែរទឹកខាងក្រោមទេ, ប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីនៃទន្លេមេគ្គ ដែលរួមបញ្ចូលទាំងបឹងទន្លេសាបផងដែរ។ (តាមការស្រាវជ្រាវរបស់អង្គការទន្លេអន្តរជាតិ ឆ្នាំ២០១៤)។ ទឹក និងដីមានជីជាតិ ដែលធ្លាប់ប្រើប្រាស់សម្រាប់ធ្វើកសិកម្មនឹងត្រូវបាត់បង់ជាក់ជាមិនខាន។

**Mekong Watch**
3F Aoki Building 1-12-11 Taito
Taito-ku, Tokyo 110-0016 Japan
E-mail: info@mekongwatch.org
Website: http://www.mekongwatch.org

៥. ចំនួនសហគមន៍មូលដ្ឋានដែលរស់នៅតាមដងទន្លេសេសាន និងទន្លេស្រែពក បានប្រឆាំងជំទាស់នឹងគម្រោងទំនប់សេសានក្រោម២នេះ។ សម្លេងរបស់ពួកគេ គួរតែត្រូវបានឮ និងផ្សព្វផ្សាយយ៉ាងពិតប្រាកដនៅគ្រប់ទិសទី។ បើពុំដូច្នោះទេ ការមិនពេញចិត្ត និងការមិនទុកចិត្តចំពោះអ្នកបង្កើតគោលនយោបាយ ពីអ្នកភូមិទាំងនេះ ប្រាដកជាលេចឡើងមិនខាន។

**សារៈតារបស់គម្រោង៖**

ទំបន់វារីអគ្គិសនីសេសានក្រោម២ គឺកំពុងស្ថិតក្រោមការសាងសង់នៅក្នុងលើដងទន្លេសេសាន ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង។ វាមានប្រវែងប្រមាណជា១,៥គីឡូម៉ែត្រ ពីកន្លែងជួបប្រសព្វគ្នារវាងទន្លេសេសាន និងទន្លេស្រែពក។ គម្រោងនេះ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងខែវិច្ឆិកា ឆ្នាំ២០១២។ ការសាងសង់បានចាប់ផ្តើមនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤។

ទំនប់វារីអគ្គិសនីនេះ ត្រូវបានរំពឹងថានឹងផលិតថាមពលអគ្គិសនីបាន៤០០មេហ្គាវ៉ាត់។ ទំនប់នេះគ្រោងសាងសង់ក្នុងកម្ពស់៤០ម៉ែត្រពីដី និងមានប្រវែង៨គីឡូម៉ែត្រកាត់ទទឹងទន្លេ។ ទំបន់នេះ នឹងលិចផ្ទៃដីចំនួន៣៣៥០០ហិកតា។ ព័ត៌មាននេះ គឺយោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្នាំ២០០៨ (អ៊ីអាយអេ) ដែលធ្វើដោយខេស៊ីស៊ី ឆ្នាំ២០០៨ (Key Consultants Cambodia, 2008)។ ទោះបីជាយ៉ាងណាក៏ដោយ ព័ត៌មានលម្អិតផ្សេងៗទៀត និងបច្ចុប្បន្នកម្មនៃការរចនាប្លង់ថ្មីទាក់ទងនឹងគម្រោងនេះ គឺមិនត្រូវបានផ្សព្វផ្សាយឲ្យបានទូលំទូលាយជាសាធារណៈនោះទេ ដែលធ្វើឲ្យមានការលំបាកបំផុតក្នុងការបញ្ជាក់ ឬការកំណត់ពីផលប៉ះពាល់ដល់បរិស្ថាន និងសង្គមនោះ។

អ្នកអភិវឌ្ឍន៍គម្រោងទំនប់វារីអគ្គិសនីនេះ គឺជាក្រុមហ៊ុនទំបន់វារីអគ្គិសនីសេសានក្រោម២។ វាជាការវិនិយោគបណ្តាក់ទុនរួមគ្នាមួយរវាងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបកម្ពុជា ដែលមានភាគហ៊ុន(៣៩%), ក្រុមហ៊ុនចិន ឆៃណាហាយដ្រូឡានឆាង អ៊ិនធើណាសសើណល់ អែនជី (China's Hydrolancang International Energy)ជា

**Mekong Watch**
3F Aoki Building 1-12-11 Taito
Taito-ku, Tokyo 110-0016 Japan
E-mail: info@mekongwatch.org
Website: http://www.mekongwatch.org

កូនក្រុមសម្ព័ន្ធរបស់ក្រុមហ៊ុន ហួនីងគ្រុប (Huaneng Group)ដែលមានភាគហ៊ុន(៥១%) និងក្រុមហ៊ុន វៀតណាម អ៊ីវីអ៊ឹន អ៊ិនធើណាសសើណាល់ ចួញស្តក់ ខមផានណី (EVN International Joint Stock Company) ដែលជាកូនក្រុមសម្ព័ន្ធរបស់អគ្គិសនីប្រទេសវៀតណាម (EVN)មានភាគហ៊ុន(១០%)។

## ឯកសារយោង៖

Baird I. G. 2009. Best practices in compensation and resettlement for large dams: The case of the planned lower Sesan 2 hydropower project in northeastern Cambodia. The River Coalition in Cambodia, Phnom Penh: Cambodia.
https://www.academia.edu/1049246/Best_Practices_in_Compensation_and_Resettlement_for_Large_Dams_The_Case_of_the_Planned_Lower_Sesan_2_Hydropower_Project_in_Northeastern_Cambodia

Baran, Eric et al. 2013. Fish and fisheries in the Sekong, Sesan and Srepok Basins (3S Rivers, Mekong Watershed), with special reference to the Sesan River. Mekong Challenge Program for Water and Food Project 3: Optimising cascades of hydropower for multiple use. International Centre for Environmental Management.
http://www.optimisingcascades.org/wp-content/uploads/2013/11/F_E-2.-Fish-and-fisheries-in-the-Sesan-river-basin.pdf

Inland Fisheries Research and Development Institute. 2013. Food and nutrition security vulnerability to mainstream hydropower dam development in Cambodia. Synthesis report of the FiA/Danida/WWF/Oxfam project “Food and nutrition security vulnerability to mainstream hydropower dam development in Cambodia”. Inland Fisheries Research and Development Institute, Fisheries Administration, Phnom Penh: Cambodia.
https://www.oxfam.org.au/wp-content/uploads/2014/02/pdf_food-and-nutrition-for-print-2.pdf

International Rivers. 2014. Starving the Mekong: Expected social and environmental impacts from construction and operation of the Lower Sesan II Dam. California: International Rivers.
http://www.internationalrivers.org/files/attached-files/starving_the_mekong_2.pdf

Key Consultants Cambodia. 2008. Environmental impact assessment for feasibility study of lower Sesan2 hydropower project, Stung Treng province, Cambodia. Power Engineering Consulting Joint Stock Company1-Vietnam and Key Consultants Cambodia.

Ziv, G. et al. 2012. Trading-off fish biodiversity, food security, and hydropower in the Mekong River Basin. Proceedings of the National Academy of Science 109.15: 5609-5614.
http://www.pnas.org/content/109/15/5609.full